**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយប្តូរឈ្មោះអនុវិទ្យាល័យកោះចូរ៉ាមទៅជា «**អនុវិទ្យាល័យ ម៉ុនរ៉ានី ហ៊ុន សែន កោះចូរ៉ាម** » ចាប់ពីឆ្នាំសិក្សា ១៩៩៥–៩៦ តទៅ ។

**ប្រការ ២** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា –ប្រធានមន្ទីរអប់រំយុវជន និង កីឡាខេត្តកណ្តាល និង នាយកអនុ – វិទ្យាល័យ **ម៉ុនរ៉ានី ហ៊ុន សែន កោះចូរ៉ាម** មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ហត្ថលេខា និង ត្រា

**តុល ឡោះ**

* * *

## ៦–ទីស្តីការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

## ប្រកាស

ភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ៤៦៤ សករ.**

**ស្តីពីការតែងតាំងទីប្រឹក្សាក្លូងការ**

**បញ្ជូនពលករខ្មែរទៅធ្វើការនៅកោះតៃវ៉ាន់**

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១២៩៩៤
- បានឃើញព្រះរាជក្រមលេខ នស.រកម. ០១៩៦.១៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាល ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេស
- តាមសំណើរបស់លោក ស៊ុន លីសេង នាយកក្រុមហ៊ុន ខេមថាយម៉ែនផាវឺរ ចុះថ្ងៃ ទី ០៤ ខែ មេសា ឆ្នាំ ១៩៩៦ ។

**សម្រេច**

**ប្រការ ១** : តែងតាំងលោក **ឆាត ឆាយឆប់រ៉ាក់** (**CHAT CHICHOPRAK**) ហៅ ហួង យ៉េនហុង (**HUANG YENHONG**) អនុប្រធានក្រុមហ៊ុនខេមថាយម៉ែនផាវឺរជាទីប្រឹក្សានៃរដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន ក្នុងការបញ្ជូនពលករខ្មែរអោយប្រើទៅធ្វើការនៅកោះតៃវ៉ាន់ ។

**ប្រការ ២** : លោក **ឆាត ឆាយឆប់រ៉ាក់** ដែលជាទីប្រឹក្សានេះ ត្រូវមានភារកិច្ចដូចតទៅ ÷

១-ទំនាក់ទំនងជាមួយអាជ្ញាធរមានសមត្ថកិច្ចតៃវ៉ាន់ អោយពលករខ្មែរបានចូលទៅបណ្តុះបណ្តាលដើម្បីធ្វើការ ឬទៅធ្វើការនៅទីនោះដោយស្របច្បាប់ ។

២-ទំនាក់ទំនងជាមួយអាជ្ញាធរមានសមត្ថកិច្ចតៃវ៉ាន់ និងបណ្តារោងចក្រសហគ្រាសដើម្បីបាន quota (ចំនួនកំរិតកំណត់) ពិតប្រាកដក្នុងការបញ្ចូលពលករខ្មែរទៅធ្វើការនៅទីនោះ ។

៣-ក្រោយពេលបានការអនុញ្ញាតជាផ្លូវការពី អាជ្ញារមានសមត្ថកិច្ចតៃវ៉ាន់អោយនាំពលករខ្មែរ ទៅធ្វើការនៅទីនោះហើយ ត្រូវរៀបចំបង្កើតការិយាល័យទំនាក់ទំនងមួយនៅតៃវ៉ាន់ដើម្បីគ្រប់គ្រងពលករទាំងនោះ ។

៤-ទទួលអនុវត្តនូវកិច្ចការផ្សេងៗទៀតជាចាំបាច់ដែលក្រសួងតំរូវអោយធ្វើទាក់ទងទៅនឹងការ បញ្ជូនពលករនេះ ។

**ប្រការ ៣** : លោក **ឆាត ឆាយឆប់រ៉ាក់** ត្រូវអនុវត្តអោយបានល្អនូវភារកិច្ចទាំងបួនដែលបានកំណត់ក្នុងប្រការ ២ ។ ចំពោះភារកិច្ចណាដែលមិនបានចែងច្បាស់ក្នុងប្រការ២ លោក

**ឆាន ឆាយឆប់រ៉ាក់** ត្រូវពិភាក្សាសុំការយល់ព្រមជាមុនពីក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជនសិនទើប អនុវត្តបាន ។

**ប្រការ ៤** : រាល់ការអនុវត្តន៍ខុសពីភារកិច្ចដែលបានកំណត់ខាងលើ ក្រសួងពុំទទួលខុសត្រូវឡើយហើយ ក្នុងករណីចាំបាច់ក្រសួងនឹងសំរេចលុបប្រកាសនេះជាស្ថាពរ លោក **ឆាន ឆាយឆប់រ៉ាក់** ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ។

**ប្រការ ៥** : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ស៊ុយ សែម**